# មេរៀនទី ២

# ការយល់ដឹងពីការគ្រប់គ្រងគ្រោះមហន្តរាយ (ទឹកជំនន់)

## Module 2

## Understanding Concept of Disaster Management (Flood)

# ការយល់ដឹងការគ្រប់គ្រងគ្រោះមហន្តរាយ

គេថា “ការគ្រប់គ្រងគ្រោះទឹកជំនន់ “ ជាការទប់ស្កាត់មិនអោយទឹកកើតឡើងជាដាច់ខាត

គេថា “ការគ្រប់គ្រងគ្រោះទឹកជំនន់“ អោយតែមានអំណោយចែកជូនជនរងគ្រោះជាការស្រេច



# ការគ្រប់គ្រងគ្រោះមហន្តរាយ “ទឹកជំនន់”

ជាបណ្តុំនៃវិធានការ ឬ សកម្មភាព ដែលគេរៀបចំឡើង ដើម្បីអនុវត្តទាំង មុនពេល ក្នុងពេល និង ក្រោយពេល មានគ្រោះមហន្តរាយកើតឡើង សំដៅកាត់បន្ថយផលប៉ះពាល់អោយមានប្រសិទ្ធិភាព ទាន់ពេល និង កំរិតប៉ះពាល់តិចតួចបំផុត ។ វិធានការរួមមាន ត្រៀមបង្ការ ការពារ កាត់បន្ថយ ឆ្លើយតប សង្គ្រោះបន្ទាន់ និង ស្តារ ឬ ជួសជុលឡើងវិញ។

# មូលហេតុអ្វីបានជាត្រូវធ្វើការងារគ្រប់គ្រងគ្រោះមហន្តរាយ “ទឹកជំនន់”

គេថា“ មិនចាំបាច់ធ្វើការងារគ្រប់គ្រងគ្រោះ
ទឹកជំនន់ ធ្វើអ្វី បើប្រជាជនធ្លាប់រស់នៅ
ជាមួយទឹកជំនន់ តាំងពីដូនតាគេមកម្លេះ
”

គេថា“ មិនចាំបាច់ធ្វើការងារគ្រប់គ្រងគ្រោះ
ទឹកជំនន់ ធ្វើអ្វី ព្រោះប្រជាជន នៅតាម
ដងទន្លេចង់បានតែទឹកធំ ងាយស្រួល
ក្នុង ការបង្កបង្កើតផល និង ផលដំណាំ
បានកើនឡើង ”




មូលហេតុអ្វីបានជាត្រូវធ្វើការខារគ្រប់គ្រងគ្រោះមហន្តរាយ “ទឹកជំនន់”
ទឹកជំនន់
រំខានដល់ការ
អភិវឌ្ឍន៏សង្គម
បំផ្លាញសមិទ្ធិផលនាន
ា
ហេដ្ឋារចនាសម្ព័ន្ធ
អ្នកក្រីក្រ
អ្នកមាន
ដំណាំកសិកម្ម
ក្មេង ៗ
សត្វចិញ្ចឹម
មនុស្សចាស់ៗ
ស្ត្រីមានផ្ទៃពោ
ះ
ស្ត្រីមេម៉ាយក្រីក្រ
មានកូនច្រើន
អ្នកមានជំងឺ
បាត់បង់ប្រាក់ចំនូល
និង ការងារ

# ការវិភាគលើដំណាក់កាលនៃការគ្រប់គ្រងគ្រោះមហន្តរាយ “ទឹកជំនន់”




តាមបទពិសោធន៍របស់លោក-អ្នក តើដំណាក់កាលណាមួយសំខាន់ និង ចាំបាច់ នៅក្នុងការងារគ្រប់គ្រងគ្រោះមហន្តរាយ “ទឹកជំនន់” ?

# ដំណាក់កាលមុនគ្រោះមហន្តរាយ

## ការការពារ

ជាវិធានការសំរាប់ការពារជាអចិន្ត្រៃយ៍ ដើម្បីទប់ស្កាត់ មិនអោយមុខសញ្ញាគ្រោះថ្នាក់កើតឡើង ឬ កុំអោយមុខសញ្ញាគ្រោះថ្នាក់ក្លាយជាគ្រោះមហន្តរាយ ។ វិធានការមានពីរបែបសំខាន់ ៗ គឺ :

- បែបហេដ្ឋារចនាសម្ព័ន្ធ (ទំនប់ ប្រឡាយ..)
- បែបមិនមែនហេដ្ឋារចនាសម្ព័ន្ធ (អប់រំ ផ្សព្វផ្សាយ រៀបចំគោលនយោបាយ.......ល)




ការការពារគ្រោះមហន្តរាយ

# ដំណាក់កាលមុនគ្រោះមហន្តរាយ




ការកាត់បន្ថយគ្រោះមហន្តរាយ

## ការកាត់បន្ថយ

ជាវិធានការដែលគេធ្វើទាំងមុនពេល និង ក្នុងពេលមានមុខសញ្ញាគ្រោះថ្នាក់កើតឡើង ដើម្បីកាត់បន្ថយឥទ្ធិពល និង ផលប៉ះពាល់របស់មុខសញ្ញាបង្កគ្រោះថ្នាក់ ។ វិធានការនេះក៏អាចធ្វើបានតាមពីរបែបសំខាន់ដែរគឺ :

១. បែបហេដ្ឋារចនាសម្ព័ន្ធ (ទប់ទំនប់ ដាក់បាវខ្សាច់ ....)

២. មិនមែនហេដ្ឋារចនាសម្ព័ន្ធ (អប់រំ ផ្សព្វផ្សាយ បណ្តុះបណ្តាល...........)

# ដំណាក់កាលមុនគ្រោះមហន្តរាយ

## ការត្រៀមបង្ការ

ជាបណ្តុំនៃវិធានការនានា ដែលគេបានរៀបចំទុកជាមុន មុនពេលមានមុខសញ្ញាគ្រោះថ្នាក់កើតឡើង *ដើម្បីធានា ធ្វើអោយការឆ្លើយប និងសង្គ្រោះ អនុវត្តមានប្រសិទ្ធិភាព និង ទាន់ពេលវេលា នៅពេលណាដែលមានមុខសញ្ញាគ្រោះថ្នាក់ កើតឡើង ។*



# ដំណាក់កាលមុនគ្រោះមហន្តរាយ

- **ការផ្សព្វផ្សាយ និង បង្កើនការយល់ដឹង**

ជាវិធានការត្រៀមបង្ការមួយ ដែលគេត្រូវធ្វើសំដៅបង្កើនការយល់ដឹងដល់ប្រជាជន ដែលរស់នៅតំបន់ប្រឈមមុខនឹងមុខសញ្ញាគ្រោះថ្នាក់ ដើម្បីអោយគេបានយល់ដឹងពីមុខសញ្ញាគ្រោះថ្នាក់ ឥទ្ធពលរបសវា ពេលវេលាដែលវាកើត គ្រោះថ្នាក់ជាយថាហេតុដែលអាចគំរាមកំហែង និង ដើម្បីអប់រំផ្សព្វផ្សាយពីវិធានការសមស្រប ក្នុងការត្រៀមជាមុន ដើម្បីការកាត់បន្ថយផលប៉ះពាល់ដល់អាយុជីវិតហេដ្ឋារចនាសម្ព័ន្ធ



# ដំណាក់កាលមុនគ្រោះមហន្តរាយ

- **ការបណ្តុះបណ្តាល និង ការបង្កើនសមត្ថភាព**

ជាការពង្រឹង ឬ បង្កើនសមត្ថភាពដល់ស្ថាប័ន អាជ្ញាធរ មូលដ្ឋាន និង ក្រុមដែលទទួលខុសត្រូវ ដើម្បីអោយគេ អាចមានសមត្ថភាព ចំណេះដឹង លទ្ធភាពគ្រប់គ្រាន់ ក្នុងការអនុវត្តន៍ការងារ ។ ចំនុចសំខាន់ នៃការបណ្តុះបណ្តាល ត្រូវធ្វើយ៉ាងណាអោយវាអាចឆ្លើយតបនឹងសេចក្តីត្រូវការរបស់អ្នកអនុវត្តការងារជាក់ស្តែង ពោលគឺចំណេះដឹង និង បទពិសោធន៍ជាក់ស្តែង ។



# ដំណាក់កាល កំពុងមានគ្រោះមហន្តរាយ

- **ការឆ្លើយតប និង សង្គ្រោះបន្ទាន់**

ជាវិធានការបន្ទាន់ និង ចាំបាច់ត្រូវធ្វើនៅពេលដែលមុខសញ្ញាគ្រោះថ្នាក់បានកើតឡើង ដើម្បីបញ្ចៀស និង កាត់បន្ថយផលប៉ះពាល់ និង បាត់បង់អាយុជីវិតមនុស្ស សត្វ និង ទ្រព្យសម្បត្តិ អោយមានកំរិតតិចតួច ។ វិធានឆ្លើយតប និង សង្គ្រោះ រួមមាន :

- ការស្រាវជ្រាវ និង រុករកសង្គ្រោះ
- ការជម្លៀស
- ការផ្តល់ពត៌មានជាមុនពីគ្រោះថ្នាក់
- ការផ្តល់ជំរក
- ការផ្តល់ទឹកស្អាត
- ស្បៀងអាហារ




ការឆ្លើយតបគ្រោះមហន្តរាយ

# ដំណាក់កាល  កំពុងមានគ្រោះមហន្តរាយ

● **ព្យាករណ៍  និង  ការផ្តល់ពត៏មានជាមុន**

ជាវិធានការដែលគេធ្វើដើម្បីផ្តល់ពតិមានស្ដីពីការកើតឡើងនៃមុខសញ្ញាគ្រោះថ្នាក់   ដូចជា   ពេលវេលាដែលវាកើត ឥទ្ធិពល ល្បឿន ផលប៉ះពាល់របស់វា ដល់ស្ថាប័នអាជ្ញាធរមូលដ្ឋាន ក្រុមទទួលខុសត្រូវ និង ប្រជាជនដែលនៅតាមតំបន់ប្រឈមមុខនឹងមុខសញ្ញាគ្រោះថ្នាក់  ដើម្បីអោយធ្វើការប្រុងប្រយ័ត្ន   ត្រៀមវិធានឆ្លើយតប  និង ទប់ស្កាត់ទៅនឹងស្ថានភាពជាក់ស្តែង ។



# ដំណាក់កាល កំពុងមានគ្រោះមហន្តរាយ



- **ស្រាវជ្រាវ និង រុករកសង្គ្រោះ**

ជាវិធានការស្រាវជ្រាវ និង រុករកសង្គ្រោះជនរងគ្រោះដែលរស់នៅតំបន់ដែលទទួលរងគ្រោះថ្នាក់ ឬ ការស្វែងរកជនរងគ្រោះដែលបាត់ខ្លួន ក្នុងពេល និង ក្រោយពេលគ្រោះមហន្តរាយកើតឡើង។

- **ការជម្លៀស**

ជាការដឹកជញ្ជូន ឬ ការបញ្ជូនប្រជាជនដែលរស់នៅតំបន់ដែលមានការគំរាមកំហែងដោយមុខសញ្ញាគ្រោះថ្នាក់ ទៅដាក់នៅទីកន្លែងដែលមានសុវត្ថិភាពអាចរួចផុតពីគ្រោះថ្នាក់ផ្សេងៗ



# ដំណាក់កាល  កំពុងមានគ្រោះមហន្តរាយ

● វិធានការកាត់បន្ថយផលប៉ះពាល់គ្រោះមហន្តរាយ នៅពេលដែលមុខសញ្ញាគ្រោះថ្នាក់បានកើតឡើងហើយ





● វិធានការកាត់បន្ថយមុខសញ្ញាគ្រោះថ្នាក់ មិនទាន់បានកើតឡើង

# ដំណាក់កាល ក្រោយគ្រោះមហន្តរាយ

- **ការស្តារ ឬ ជួសជុលឡើងវិញ**

ជាវិធានការដែលគេធ្វើក្រោយពេលមានគ្រោះមហន្តរាយ ដើម្បីធ្វើអោយស្ថានភាពអាចវិលទៅរកភាពដើមប្រសើរឡើងវិញ ។ ការងារស្តារ និង ជួសជុលឡើងវិញ រួមមាន ការជួសជុលផ្លូវ ស្ពាន ប្រលាយទឹក ដាំដំណាំឡើងវិញ និង ធ្វើអោយដំណើរការអភិវឌ្ឍន៏សេដ្ឋកិច្ចសង្គមប្រព្រឹត្តិទៅដូចដើមឡើងវិញ។



ការស្តារ ឬ ការស្តារឡើងវិញ